# សម្ពន្ធភាពដើម្បីអភិរក្សធនធានជលផល

Fisheries Action Coalition Team (FACT)

## វគ្គហ្វឹកហ្វឺន :

វគ្គបណ្តុះបណ្តាលអំពីមូលដ្ឋានគ្រឹះក្នុងការស្វែងយល់អំពីច្បាប់
ដល់ជនបង្គោល សហគមន៍នេសាទធ្វើថ្ងៃទី ១៦-១៨ ខែ កុម្ភៈ
ឆ្នាំ ២០០៤ នៅសាលាបណ្តុះបណ្តាលមន្ទីរសុខាភិបាលខេត្តកំពង់ធំ




រៀបចំដោយ ឯម ចន្ទ័ណារិទ្ធ

# របាយការណ៍

**វគ្គហ្វឹកហ្វឺនស្តីពី មូលដ្ឋានគ្រឹះក្នុងការស្វែងយល់នូវអំពីច្បាប់ ដល់ជនបង្គោល តំណាង សហគមន៍នេសាទ នាថ្ងៃទី ១៦-១៨ ខែ កុម្ភៈ ឆ្នាំ ២០០៤ ទីកន្លែង សាលាបណ្តុះបណ្តាលមន្ទីរសុខាភិបាលខេត្តកំពង់ធំ**

## ក- សេចក្តីផ្តើម

អាងបឹងទន្លេសាប ជាអាងមួយដែលប្រជាជនកម្ពុជាទាំងអស់ចាត់ទុកថាធនាគាររបស់គាត់ ច្រើនទសវត្សមកហើយ ប្រជាជនរស់ជុំវិញអាងនេះ មានមុខរបរចំបងគឺនេសាទត្រី ធ្វើស្រែប្រាំង និង ធ្វើចំការចន្លិចបន្តួច ។

ក្រោយសង្គ្រាមស៊ីវិលអូសបន្លាយជាច្រើនឆ្នាំកន្លង ប្រជានេសាទដែលរស់ជុំវិញអាងបឹងទន្លេសាបបន្សល់នៅ ស្ត្រីមេម៉ាយ កុមារកំព្រា សុខភាពទ្រុឌទ្រោម ភាពក្រីក្រកាន់តែកើនឡើង ជាពិសេសសេវាការផ្សព្វផ្សាយច្បាប់ ឬ ពត៌មានផ្សេងៗ និង ការអប់រំនៅមានកំរិតដល់ប្រជានេសាទជុំវិញអាងនេះ ជាមូលហេតុជាច្រើនដែលធ្វើអោយមានទំនាស់ជាច្រើនដូចជា: រវាងអ្នកមានអំណាចទៅប្រជានេសាទក្រីក្រ រវាងប្រជានេសាទនិងប្រជានេសាទ អ្នកប្រើប្រាស់ឧបករណ៍លក្ខណៈគ្រួសារ និងឧបករណ៍សិប្បកម្ម ភាពអនាធិបតេយ្យក្នុងប្រើប្រាស់ឧបករណ៍ខុសច្បាប់ដូចជា: ការឆក់ ការដងកូនត្រី.... និង ការកើនឡើងកាប់ព្រៃលិចទឹក ។

កាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ សម្តេចនាយករដ្ឋមន្ត្រីកម្ពុជាបានចុះហត្ថលេខាលើអនុក្រិត្យស្តីពី ការកាត់បន្ថយដែនឡូត៍នេសាទពីនាទីឡូត៍ ដើម្បីប្រជានេសាទធ្វើនេសាទលក្ខណៈគ្រួសារវិញ ។ អង្គការមិនមែនរដ្ឋាភិបាល និង សហគមន៍នេសាទ នៅតាមមូលដ្ឋានបានអបអរសាទរចំពោះកំណែទំរង់ថា ជាជំហានដ៏សំខាន់មួយក្នុងការ កាត់បន្ថយភាពក្រីក្រ។ តែអង្គការ NGOs បានកត់សំគាល់ឃើញការកសាងសមត្ថភាពដល់សហគមន៍នេសាទនៅមានកំរិត ។

ដូច្នេះអង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល ចូលរួមកសាងសមត្ថភាពដល់ប្រជានេសាទ និង សហគមន៍នេសាទ៦ខេត្តជុំវិញអាងបឹងទន្លេសាប បើកវគ្គហ្វឹកហ្វឺនស្តីពី មូលដ្ឋានគ្រឹះក្នុងការស្វែងយល់នូវអំពីច្បាប់ ដល់ជនបង្គោល តំណាង សហគមន៍នេសាទ នាថ្ងៃទី ១៦-១៨ ខែ កុម្ភៈ ឆ្នាំ ២០០៤ ទីកន្លែង សាលាបណ្តុះបណ្តាលមន្ទីរសុខាភិបាលខេត្តកំពង់ធំ ។

## ខ- គោលដៅរបស់គំរោង

ដើម្បីពង្រឹងសមត្ថភាពជនបង្គោលប្រជានេសាទជុំវិញបឹងទន្លេសាប ដើម្បីជួយផ្សព្វផ្សាយដល់សហគមន៍ ។

## គ. គោលដៅ

. ពង្រឹងសមត្ថភាពរបស់បណ្តាញប្រជាមេសាទ និង ជនបង្គោល

. ការយល់ដឹងដល់បណ្តាញប្រជាមេសាទ និង ជនបង្គោលស្តីពី មូលដ្ឋានគ្រឹះច្បាប់ និង ជាអ្នកដើរតួអង្គសំខាន់ផ្សព្វផ្សាយដល់សហគមន៍ ។

. ប្រជាមេសាទនៅជុំវិញបឹងទន្លេសាបបានទទួលការយល់ដឹងស្តីពី មូលដ្ឋានគ្រឹះច្បាប់នៅតាមសហគមន៍របស់គាត់ ។

## ឃ. សមាសភាពចូល :

. លោក ហោ នាថ ប្រធាន ប្រចាំខេត្តកំពង់ធំ ជាគ្រូឧទេសនាម

. លោក ពូច សាឡឿន ប្រធាន តុលាការខេត្តកំពង់ធំ ជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាល

. លោក ឯមចន្ទ័ណារិទ្ធ អ្នកសំរបសំរួលរួម នៃ វគ្គ

. លោក ហុយ ថុល ស្មុគ្រ័កំណត់ត្រា

| ល.រ | មកពីខេត្ត | ចំនួនអ្នកចូលរួម |
|---|---|---|
| ១ | បន្ទាយមានជ័យ | ៣ នាក់ |
| ២ | បាត់ដំបង | ៦ នាក់ |
| ៣ | ពោធិសាត់ | ៣ នាក់ |
| ៤ | កំពង់ឆ្នាំង | ៣ នាក់ |
| ៥ | កំពង់ធំ | ៤ នាក់ |
| ៦ | សៀមរាប | ៤ នាក់ |
| សរុប | | ២២ នាក់(៣នាក់) |

## ង. ការរំពឹងទុក នៃ វគ្គ

. បានយល់ដឹងអំពីអំពីច្បាប់ / តុលាការ / សិទ្ធិប្រជាពលរដ្ឋ

. មានមូលដ្ឋានគ្រឹះក្នុងការផ្សព្វផ្សាយដល់សហគមន៍

. ការអនុវត្តន៍សមស្របតាមវិធីវិធី នៃ ច្បាប់

. ក្រោយពីវគ្គ បណ្តុះបណ្តាលយកចំណេះនេះទៅផ្សព្វផ្សាយក្នុង និង ក្រៅសហគមន៍

. សង្ឃឹមថា និង មានការគោរពសិទ្ធិទៅវិញទៅមកក្នុងការគោរពច្បាប់

. យើងបានស្គាល់គ្នាប្រជាមេសាទជុំវិញទន្លេសាប

. យល់ដឹងពីតួនាទី ភារកិច្ចអំពីជនបង្គោល ដើម្បីផ្សព្វផ្សាយដល់សហគមន៍

# វគ្គបណ្តុះបណ្តាលស្តីពី

## សំរាប់មូលដ្ឋានគ្រឹះក្នុងការស្វែងយល់នូវច្បាប់ដល់ជនបង្គោលតំណាង

## សហគមន៍នេសាទជុំវិញបឹងទន្លេសាប

ថ្ងៃទី ១៦-១៨ ខែ មិនា ឆ្នាំ ២០០៤

| ម៉ោង | ប្រធានបទ | អ្នកសំរបសំរួល |
|---|---|---|
| | ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៤ | |
| ៨:០០ - ៩:០០ | - ការបើកវគ្គបណ្តុះបណ្តាល<br>- ការណែនាំអោយស្គាល់គ្នា<br>- ការរំពឹងទុក និង វិន័យរបស់សិក្ខាកាមសំរាប់វគ្គទាំងមូល គោលបំណង និង កម្មវិធីសំរាប់វគ្គ | - ឯម ចន្ទ័ណារិទ្ធ<br>- ហ៊ុយ ថុល |
| ១០:០០ - ១០:២០ | សំរាកពិសារអាហារសំរន់ | |
| ១០:២០ - ១២:០០ | - ស្តីពី សិទ្ធិ ពលរដ្ឋ និង សិទ្ធិនយោបាយ | - ហោ នាថ<br>- ឯម ចន្ទ័ណារិទ្ធ |
| ១២:០០ - ២:០០ | សំរាកពិសារអាហារថ្ងៃត្រង់ | |
| ២:០០ - ២:២០ | - លេងល្បែងបង្កើនថាមពល | - ហ៊ុយ ថុល |
| ២:២០ - ៥:០០ | - ស្តីពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ( បន្ត)<br>- ស្តីពី សិទ្ធិសេដ្ឋកិច្ច និង វប្បធម៌ | - ហោ នាថ<br>- ឯម ចន្ទ័ណារិទ្ធ |
| | ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៤ | |
| ៨:០០ - ៨:២០ | - រំលឹកមេរៀន | - ហោ នាថ |
| ៨:២០ - ១០:០០ | - ស្តីពី ករណីកិច្ចរបស់ប្រជាពលរដ្ឋ<br>. អំពីនីតិវិធីច្បាប់ព្រហ្មទណ្ឌ<br>. ការសរសេរពាក្យបណ្តឹងព្រហ្មទណ្ឌ | - ហោ នាថ<br>- ឯម ចន្ទ័ណារិទ្ធ |
| ១០:០០-១០:២០ | សំរាកពិសារអាហារសំរន់ | |
| ១០:២០-១២:០០ | - ស្តីពី ករណីកិច្ចរបស់ប្រជាពលរដ្ឋ<br>. ការសរសេរពាក្យបណ្តឹងរដ្ឋប្បវេណី<br>. ការសរសេរពាក្យបណ្តឹងសាទុក្ខឧទ្ធរណ៍ | - ហោ នាថ<br>- ឯម ចន្ទ័ណារិទ្ធ |

| | | |
|---|---|---|
| ១២:០០-២:០០ | **សំរាកពិសារអាហារថ្ងៃត្រង់** | |
| ២:០០-២:២០ | - លេងល្បែងបង្កើនថាមពល | - ហ៊ុយ ថុល |
| ២:២០-៥:០០ | - ស្ដីពី ការផ្លាស់ប្តូររបស់ប្រជាពលរដ្ឋ<br>ការសរសេរពាក្យបណ្តឹងតុលាការកំពូល<br>- រចនាសម្ព័ន្ធតុលាការ | - ហោ នាថ<br>- ឯម ចន្ទ័ណារិទ្ធ |
| **ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៤** | | |
| ៨:០០-៨:២០ | - រំលឹកមេរៀន | - ហោ នាថ |
| ៨:២០ - ១០:០០ | - រចនាសម្ព័ន្ធតុលាការ ( បន្ត ) | - ហោ នាថ<br>- ឯម ចន្ទ័ណារិទ្ធ |
| ១០:០០-១០:២០ | **ពិសារអាហារសំរន់** | |
| ១០:២០-១២:០០ | - នីតិវិធី នៃ ច្បាប់ | - ហោ នាថ<br>- ឯម ចន្ទ័ណារិទ្ធ |
| ១២:០០-២:០០ | **សំរាកពិសារអាហារថ្ងៃត្រង់** | |
| ២:០០-៤:០០ | - សំនួរចំលើយនីតិវិធីច្បាប់ | - លោក ប្រធានតុលាការខេត្តកំពង់ធំ |
| ៤:០០-៥:០០ | **វាយតំលៃបញ្ចប់វគ្គ** | |

## មេរៀនទី ១

# ស្តីពីសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ

**អ្វីទៅសិទ្ធិមនុស្ស :** សិទ្ធិមនុស្សនេះបានចែងក្នុងធម្មនុញ្ញ នៃ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្សកតិការសញ្ញាព្រមទាំង អនុសញ្ញាទាំងឡាយដែលទាក់ទងទៅនិង សិទ្ធិមនុស្ស សិទ្ធិស្ត្រី និង សិទ្ធិកុមារ ។ អង្គការសហប្រជាជាតិអនាម័តអោយប្រើប្រាស់នាថ្ងៃទី ១៦ ខែ ធ្នូ ១៩៦៦ ព្រះរាជណាចក្រកម្ពុជាទទួលយក និង ដាក់បញ្ចូលធម្មនុញ្ញជំពូកទី ៣ មាត្រា៣១. មាត្រា ៣២ ។

- **និយមន័យសិទ្ធិមនុស្ស :**

សិទ្ធិមនុស្សត្រូវបានគេអោយនិយមន័យយ៉ាងសមញ្ញថា : សិទ្ធិមនុស្សជាអ្វី១ ដែលសំខាន់ចាំបាច់សំរាប់ការរស់រានមានជីវិតប្រកបដោយតម្លៃ និង សេចក្តីថ្លៃថ្នូរ ក្នុងភាពមនុស្សទាំងពីកំណើតមក ។

១. **សិទ្ធិពលរដ្ឋ :** *មានក្នុងរដ្ឋធម្មនុញ្ញជំពូក៣ មាត្រា៣១ និង មាត្រា៣២*

**មាត្រា ៣១ -**

ព្រះរាជណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដូចមានចែង ក្នុងធម្មនុញ្ញ នៃ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស និង កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទង ទៅ នឹង សិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ។ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខ ច្បាប់មានសិទ្ធិ សេរីភាព និងករណី យកិច្ចដូចគ្នាទាំងអស់ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈ សង្គមធនធាន ឬ ស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ដែលប្រព្រឹត្តមានលក្ខខណ្ឌ កំណត់ក្នុងច្បាប់ ។

**មាត្រា ៣២ -**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។ ទោសប្រហារជីវិតមិនត្រូវអោយមានឡើយ ។

២. **សិទ្ធិនយោបាយ :** *មានក្នុងរដ្ឋធម្មនុញ្ញជំពូក ៣ មាត្រា៣៤ និង មាត្រា៣៥*

**មាត្រា ៣៤-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និង អាចឈរឈ្មោះអោយ គេបោះឆ្នោះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច១៨ឆ្នាំមានសិទ្ធិបោះឆ្នោត

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំអាចឈរឈ្មោះ អោយគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំអាចឈរឈ្មោះ អោយគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទបញ្ញត្តិបន្ទយបោះឆ្នោត និង សិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាព នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និង ដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

# មេរៀន

## មេរៀនទី ២

# ស្តីពី សិទ្ធិសេដ្ឋកិច្ចសង្គម និង វប្បធម៌

**១. សិទ្ធិសេដ្ឋកិច្ច** : មានក្នុងរដ្ឋធម្មនុញ្ញជំពូក ៣ មាត្រា៣៦ និង មាត្រា៤៤

**មាត្រា ៣៦.**

ប្រជាពលរដ្ឋខ្មែរពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាម សមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារ ដូចគ្នា

ការងារមេផ្ទះមានតំលៃស្មើគ្នាដែលមានកំរៃដែលបានមកពីការងារធ្វើខាងក្រៅ ផ្ទះ

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធទទួលការធានារ៉ាប់រងសង្គមអត្ថប្រយោ ជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិក សហជីពនេះ

ការរៀបចំ និង ការប្រព្រឹត្តទៅនៃសហជីព និងមានកំណត់ក្នុងច្បាប់

**២. មាត្រា ៤៤.**

ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ តែរូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានជាសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់ កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធឯកជនស្របច្បាប់ ថិតនៅក្រោមការគាំពារ នៃច្បាប់ ។ ដែលនិង

ដកហូតកម្មសិទ្ធិអំពីឯកជនណាមួយបាននោះ ។ លុះត្រាតែផលប្រយោជន៍សាធារណៈតំរូវអោយធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណង់ជាមុនដោយសមរម្យ និង យុត្តិធម៌ ។

. **សិទ្ធិសង្គម** : *មានក្នុងរដ្ឋធម្មនុញ្ញជំពូក ៣ មាត្រា ៤០*

**មាត្រា ៤០.**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និង តាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ ប្រជាពលរដ្ឋត្រូវ បានគោរព ។ ការរក្សាសិទ្ធិមិនរំលោភ លើលំនៅឋាន និងតាំងទីលំនៅក្នុងស្ថានភាពស្រប ច្បាប់របស់ប្រជាពលរដ្ឋ

ត្រូវបានគោរព ។ ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅក្រៅប្រទេស ឬវិលត្រឡប់មកវិញបាន ។ ការរក្សាសិទ្ធិមិនរំលោភលើលំនៅឋាន ហ្នឹង អាថ៌កំបាំង នៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និង តាមទូរស័ព្ទត្រូវធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គល ត្រូវធ្វើអោយស្រប នឹង បញ្ញត្តិច្បាប់ ។

**២. សិទ្ធិវប្បធម៌ :** *មានក្នុងរដ្ឋធម្មនុញ្ញជំពូក ៣ មាត្រា៤៣ និង មាត្រា៤៨*

**១. មាត្រា ៤៣.**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។ សេរីភាពខាង ជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌដែលមិនប៉ះ ពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។

**២. មាត្រា ៤៨.**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពី កុមារ ជាពិសេសសិទ្ធិានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំ ពារក្នុងស្ថានការណ៍មានសង្គ្រាម និង ការ ការពារប្រឆាំង នឹងអាជីវកម្មសេដ្ឋកិច្ចឬ តាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើអោយខូចដល់ការអប់រំ នឹង រៀនសូត្ររបស់កុមារ ឬដែលនាំអោយអន្តរាយដល់សុខភាពកុមារ ឬ សុខមាល ភាពរស់កុមារ ។

**សរុបរួម នៃ មេរៀនស្តីពី សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ចសង្គម និង វប្បធម៌**

**៣. វិធីសំនួរបំផុសបញ្ហា**

**ដើម្បីរស់នៅជាមនុស្សកើត តើយើងត្រូវការអ្វីខ្លះ ?**

| សិទ្ធិពលរដ្ឋ និង នយោបាយ | សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ |
|---|---|
| . សិទ្ធិរស់រានមានជីវិត | . សិទ្ធិមានចំណីអាហារហូបគ្រប់គ្រាន់ |
| សិទ្ធិគ្មានការរើសអើង | . សិទ្ធិទទួលបាននូវលក្ខខណ្ឌរស់នៅសមរម្យ |
| . សិទ្ធិមិនទទួលការចាប់ខ្លួន ឃុំខ្លួន តាមអំពើចិត្ត | . សិទ្ធិមានការគាំពារខាងសុខភាព |

| | |
|---|---|
| . សិទ្ធិសេរីភាពក្នុងការដើរហើរ | . សិទ្ធិមានផ្ទះសម្បែង និង កម្មសិទ្ធិដីធ្លី |
| . សិទ្ធិមិនទទួលរងការធ្វើទារុណកម្ម | . សិទ្ធិទទួលបានការងារអប់រំ |
| . សិទ្ធិមានការប្រជុំដោយសន្តិវិធី | . សិទ្ធិមានការងារធ្វើ |
| . សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ | .សិទ្ធិមានប្រាក់កំរៃស្មើគ្នាចំពោះការងារដូចគ្នា |
| . សិទ្ធិបង្កើតគណបក្សនយោបាយ | . សិទ្ធិមិនរងការបង្ខិតបង្ខំអោយធ្វើការ ហួសកំលាំង |
| . សិទ្ធិបោះឆ្នោត និង ឈរឈ្មោះជា បេក្ខជន | . សិទ្ធិសំរាកលំហែវិស្សមកាល ឬមាតុភាព |
| . សេរីភាពក្នុងការតាំងទីលំនៅ | . សិទ្ធិសម្តែងសិល្បៈវប្បធម៌ |
| . សិទ្ធិមានកម្មសិទ្ធិ | . សិទ្ធិបង្កើតសហជីព |

ការដាក់ជំពូកធំទាំងពីរខាងលើនេះពុំមានន័យថា មានការបែងចែកដាច់ដោយ ឡែកគ្នានៃ សិទ្ធិមនុស្សទេ ព្រោះថាជំពូកទាំងនេះមានការទាក់ទងគ្នាទៅវិញទៅមក ។ សិទ្ធិទាំងអស់នេះ មានការទាក់ ទង នឹងចលនាកំរើករបស់មនុស្ស ។ ការកាត់ផ្តាច់ ឬការរឹតត្បិតសង្កត់តៅលើចលនាណាមួយអាចជាផលប៉ះពាល់ ទៅដល់ចលនាដទៃទៀត ។

**៤~ សាកលភាព នៃ សិទ្ធិមនុស្ស**

សិទ្ធិមនុស្សមានលក្ខណៈជាសាកល ពីព្រោះថាពូជពង្សមនុស្សកើតមកជាមួយ នូវរូបកាយជាមនុស្ស និង នាំមកនូវការទាមទារជាទូទៅដូចៗគ្នា ។ រូបរាងកាយ មនុស្សភ្ជាប់ខោយអវៈយវៈត្រូវការកំរើក និងការធ្វើចលនាជាធម្មជាតិ ដោយមិនត្រូវ ការអ្វីខាងក្រៅជាកម្លាំងង្ខំមកគ្របសង្កត់ជិះជាន់ ឬ ដាក់កំហិត ឬធ្វើអោយឈឺចាប់ ឡើយ ។ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា ឋានៈ វណ្ណៈ ពូជសាសន៍ ឬ ដើមកំណើតជាតិដែលមនុស្សបានកើតមកដោយមិនមានសេចក្តីប្រាថ្នាជាមុន មិនអាច យកសំអាងបង្ហាញពីភាព ខុសប្លែងគ្នាអំពីសកលភាព នៃ សិទ្ធិមនុស្សបានទេ ។

ឧទារណ៍ ប្រសិនបើអ្នកយកបារីដុតលើរាងកាយខ្លួនឯង រួចហើយបន្តធ្វើរបៀប នេះទៅលើមនុស្សណាម្នាក់ទៀតដែលមានពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ឋានៈ ពូជសាសន៍ឬដើមកំណើតជាតិខុសពីអ្នកចំលើយដែល អ្នករំពឹងនោះគឺការឈឺចាប់ដូចៗគ្នា ។

**៥~ ភាពមិនអាចកាត់ដាច់ចេញពីគ្នា នៃ សិទ្ធិមនុស្ស**

សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ និង សិទ្ធិសេដ្ឋកិច្ចសិទ្ធិសង្គម និងសិទ្ធិវប្បធម៌ មានភាពមិនអាចកាត់ដាច់ពីគ្នាបានទេ ។ សិទ្ធិពលរដ្ឋ និងនយោបាយអាចមានន័យ តិច ឬអាចមិនមានន័យ ប្រសិនបើមិនមានធនធាន

សេដ្ឋកិច្ច ដើម្បីជ្រោមជ្រែងសិទ្ធិ ទាំងនេះ ហើយដូចគ្នានេះដែរ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ឬការមានទ្រព្យសម្បត្តិនឹងអាច រលាយទៅវិញ កាលបើគ្មានការគោរពនិងការពារសិទ្ធិពលរដ្ឋនិង នយោបាយ ។ ដូចដែលបានអោយនិយមន័យខាងលើហើយថា សមិទ្ធផលសេដ្ឋកិច្ច កិច្ចការសង្គម និងខឿនវប្បធម៌ ជាតិ និងមានស្ថិរភាពអាស្រ័យដោយមានការគោរព និងការពារ សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋ ។ប៉ុន្តែពុំមែនមានន័យថា សិទ្ធិ ពលរដ្ឋ និង នយោបាយមានភាពប្រសើរជាងសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ នោះទេ ។ ពោលគឺ ជំពូកសិទ្ធិមនុស្សធំៗទាំងនោះមានការអាស្រ័យគ្នាជាចាំបាច់ទៅ វិញទៅមក ។

៦- សិទ្ធិមានជំរកសមរម្យ ឬមានកម្មសិទ្ធិដីធ្លី

មនុស្សគ្រប់ទាំងអស់ម មានសិទ្ធិមានទីលំនៅសមរម្យ និងដីធ្លី ដែលរដ្ឋមាន កតព្វកិច្ចទទួលខុសត្រូវ ។ នេះមានន័យថា គ្មានជនណាម្នាក់ទទួលរង នូវការដេក ហូតយកផ្ទះសំបែង ឬដីធ្លីដែលជាកម្មសិទ្ធិ របស់ ខ្លួន តាមអំពើចិតឡើយ ហើយអ្នក គ្មានដីធ្លី ឬផ្ទះសំបែង រដ្ឋាភិបាលមានគោល ការណ៍បែងចែកដីសម្បទាន ជូន ប្រជាពលរដ្ឋទៅតាមលក្ខណៈសមស្រម ដើម្បីមានដីធ្លី ឬផ្ទះសំបែងរស់នៅសមរម្យ ។ គ្មាន គ្រួសារម្នាក់អាច ទទួលរង នូវការបណ្តេញចេញ ពីផ្ទះសំបែង ឬដីធ្លីដោយបង្ខិតបង្ខំ ដោយមិនបានទទួលសំណងជួសជុលការខូច ខាត ថ្លៃសមស្របតាមការសុខចិត្តជាមុន នោះទេ ( *រដ្ឋធម្មនុញ្ញមាត្រា ៤៤* ) ។

មេរៀនទី ៣

# ស្តីពី ករណីកិច្ចរបស់ប្រជាពលរដ្ឋ

១- អំពីនីតិវិធីច្បាប់ព្រហ្មទណ្ឌ :( មាត្រា ១០ រដ្ឋធម្មនុញ្ញ មាត្រា ៣៨,៣៩ )

១. មាត្រា ១០- ( *បទបញ្ញត្តិស្តី ប្រពន្ធ័តុលាការច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល* )

១-១ សិទ្ធិពឹងពាក់មេធាវី ឬទីប្រឹក្សាត្រូវបានធានាជួយជនគ្រប់រូបដែលជាប់ចោទពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ ។

១-២ ទោះបីបទល្មើសនោះធ្ងន់ស្រាលយ៉ាងណាក៏ដោយ គ្មានជនណាម្នាក់ត្រូវ ជាប់ឃុំឃាំងនៅលើសទឹកដីកម្ពុជាលើសរយៈពេល ៤៨ ម៉ោង ដោយគ្មានទទួលជំនួយពីទីប្រឹក្សាពីមេធាវី ឬ តំណាងដែលបទបញ្ញត ឡើយ ។

២.មាត្រា ៣៨- ( រដ្ឋធម្មនុញ្ញ )

ច្បាប់ការពារមិនអោយមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាលរដ្ឋ ។ ការចោទប្រកាន់ ការចាប់ខ្លួន និងការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនិង អាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬ ប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬ ជាប់ពន្ធនាគារត្រូវហាមឃាត់មិន អោយធ្វើឡើយ ។ អ្នកដែដល់ អ្នករួមប្រព្រឹត្ត និង អ្នកសមគំនិតត្រូវទទួលទោស តាមច្បាប់ ។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មនត្រូវទុកជាភស្តុតាង នៃ ពិរុទ្ធភាពទេ ។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។ជនជាប់ចោទណាក៏ ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវការតុលាការ ។

៣. មាត្រា ៣៩_ ( *រដ្ឋធម្មនុញ្ញ* )

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទារសំណងជួលជុល ការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលនៃអង្គការទាំងនោះ ។ ការដោះស្រាយបន្តឹងតវ៉ានិងសំណងជួសជុល ការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

៤_ **គំរូពាក្យបណ្តឹង**

· **បណ្តឹងព្រហ្មទណ្ឌ** :បណ្តឹងព្រហ្មទណ្ឌ គឺជាបណ្តឹងពាក់ពន្ធ័រដ្ឋអាជ្ញា ។ ឧទាហរណ៍ជាបទល្មើសធ្វើអោយខូចខាចទ្រព្យសម្បត្តិសាធារណៈ ប៉ះពាលដល់ សណ្តាប់ធ្នាប់សង្គម ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>ពាក្យបណ្តឹង</u>**

ខ្ញុំបាទនាងខ្ញុំឈ្មោះ..................អាយុ......ឆ្នាំជាតិ.........មុខរបរ........
ទីលំនៅបច្ចុប្បន្ន ភូមិ.................ឃុំ..............ស្រុក............ខេត្ត........

<u>សូមគោរពចូលមក</u>

លោក:..................................................................................

សូមទានជ្រាប ។

កម្មវត្ថុ : សុំប្តឹងពីឈ្មោះ..............ភេទ.........អាយុ....ឆ្នាំជាតិ.......មុខរបរ
...................មានទីលំនៅភូមិ...........ឃុំ...........ស្រុក..........ខេត្ត.....
ពីបទ:...........................................................................។

តាមកម្មវត្ថុខាងលើ ខ្ញុំជំរាបជូនលោក...................................
បានជ្រាបដូចតទៅ ។

កាលពីថ្ងៃទី............ខែ........ឆ្នាំ ២០០... វេលាម៉ោង..... និង.....នាទី....

..............................................................................

..............................................................................

..............................................................................

..............................................................................

..............................................................................

..............................................................................

..............................................................................

..............................................................................

..............................................................................

..............................................................................

<u>សំនួមពរ</u> :

..............................................................................

..............................................................................

..............................................................................

..............................................................................

......ថ្ងៃទី......ខែ.....ឆ្នាំ.......

ស្នាមមេដៃស្តាំអ្នកថ្លឹង

. បណ្តឹងរដ្ឋប្បវេណី : បណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងឯកជន ។ ឧទាហរណ៍ដូចជា:

- បណ្តឹងកិច្ចសន្យា ( ជួល ខ្ចី អោយដោយមិនមានសំណង)
- បណ្តឹងកម្មសិទ្ធិ ( ទ្រព្យសម្បត្តិ ដីធ្លី )
- បណ្តឹងអាពាហ៍ពិពាហ៍ ( ការលែងលះ ការបែងចែកទ្រព្យសម្បត្តិ)
- បណ្តឹងកិច្ចការប្រញាប់ ( ការផ្តាច់សង្វាស់ភ្លាម១ ) ព្រោះថាបណ្តឹងនេះហើយព្រាក្នុងគ្រួសារធ្ងន់ធ្ងរ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹង

ខ្ញុំបាទនាងខ្ញុំឈ្មោះ..................អាយុ......ឆ្នាំជាតិ.........មុខរបរ.......
ទីលំនៅបច្ចុប្បន្ន ភូមិ..................ឃុំ..............ស្រុក...........ខេត្ត.......

**សូមគោរពចូលមក**

លោក:.........................................................................................

សូមទានជ្រាប ។

កម្មវត្ថុ : សុំប្តឹងពីឈ្មោះ..............ភេទ.........អាយុ....ឆ្នាំជាតិ.......មុខរបរ
..................មានទីលំនៅភូមិ...........ឃុំ..........ស្រុក..........ខេត្ត.....

តាមកម្មវត្ថុខាងលើ ខ្ញុំជំរាបជូនលោក...................................
បានជ្រាបដូចតទៅ ។

កាលពីថ្ងៃទី............ខែ........ឆ្នាំ ២០០... វេលាម៉ោង..... និង.....នាទី....
.........................................................................................
.........................................................................................
.........................................................................................
.........................................................................................
.........................................................................................
.........................................................................................
.........................................................................................
.........................................................................................
.........................................................................................
.........................................................................................

<u>សំនួមពរ</u> :

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

......ថ្ងៃទី......ខែ.....ឆ្នាំ.......

ស្នាមមេដៃស្តាំអ្នកប្តឹង

បណ្តឹងតថា : បណ្តឹងតវ៉ានេះសំរាបប្តឹងតវ៉ាពីសាលាដំបូង ( ខេត្ត ក្រុង ) ទៅសាលាឧទ្ធរណ៍តែប៉ុណ្ណោះ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

<u>**ពាក្យបណ្តឹង**</u>

ខ្ញុំបាទនាងខ្ញុំឈ្មោះ.................អាយុ......ឆ្នាំជាតិ.........មុខរបរ.......
ទីលំនៅបច្ចុប្បន្ន ភូមិ.................ឃុំ...............ស្រុក............ខេត្ត.......

<u>សូមគោរពចូលមក</u>

លោកៈ.........................................................................

សូមទានជ្រាប ។

កម្មវត្ថុ : សុំប្តឹងពីឈ្មោះ..............ភេទ.........អាយុ....ឆ្នាំជាតិ.......មុខរបរ
..................មានទីលំនៅភូមិ...........ឃុំ..........ស្រុក.........ខេត្ត.....
ពីបទៈ...........................................................................។

តាមកម្មវត្ថុខាងលើ ខ្ញុំជំរាបជូនលោក.................................

បានជ្រាបផ្លូចតទៅ ។

កាលពីថ្ងៃទី............ខែ........ឆ្នាំ ២០០... វេលាម៉ោង..... និង.....នាទី....

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

<u>សំនូមពរ</u> :

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

......ថ្ងៃទី......ខែ.....ឆ្នាំ.......

ស្នាមមេដៃស្តាំអ្នកប្តឹង

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ពាក្យបណ្ដឹងសារទុក្ខ**

ខ្ញុំបាទនាងខ្ញុំឈ្មោះ......................អាយុ......ឆ្នាំជាតិ.........មុខរបរ.......
ទីលំនៅបច្ចុប្បន្ន ភូមិ..................ឃុំ..............ស្រុក...........ខេត្ត.......

<u>សូមគោរពជូនមក</u>

លោក:......................................................................

សូមទានជ្រាប ។

កម្មវត្ថុ ៖ សុំប្ដឹងសារទុក្ខអំពីការសំរេចសំរាំងសាលដីការរបស់សាលាឧទ្ធរណ៍ទាំងមូល

តាមកម្មវត្ថុខាងលើខ្ញុំជំរាបជូនឯកឧត្ដម.......................................
បានជ្រាបដូចតទៅ ។

ចៀតកាលពីថ្ងៃទី.......ខែ........ឆ្នាំ ២០០... វេលាម៉ោង..... និង.....នាទី....
..........................................................................
..........................................................................
..........................................................................
..........................................................................
..........................................................................
..........................................................................
..........................................................................
..........................................................................
..........................................................................
..........................................................................

សំគាល់ពិនិត្យ :

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

......ថ្ងៃទី......ខែ.....ឆ្នាំ.......

ស្នាមមេដៃស្តាំអ្នកប្តឹង

# មេរៀនទី ៤ រចនាសម្ព័ន្ធតុលាការ

(បទបញ្ញត្តិ ស្តីពី ប្រពន្ធ័តុលាការច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់ប្រទេសកម្ពុជាក្នុងសម័យអន្តរកាល)

## មាត្រា១ : ឯករាជភាពនៃក្រុមចៅក្រម

១ : ឯករាជភាពនៃក្រុមចៅក្រមត្រូវតែធានាអោយមានលក្ខណៈស្របនឹង *គោលការណ៍មូលដ្ឋានស្តីអំពីឯករាជភាពនៃក្រុមចៅក្រម* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។ ចៅក្រមទាំងឡាយត្រូវកាត់ក្តីតាមភាពមិនលំអៀង ផ្អែកលើហេតុការណ៍ ដែលមាននៅចំពោះមុខ ហើយក្នុងការគោរពច្បាប់ ដោយមិនព្រមទទួលការគាបសង្កត់. ការគំរាមកំហែង ឬការបំភិតបំភ័យ. ដោយចំពោះ ឬមិនចំពោះ អំពីភាគីណាមួយក្នុងរឿងកាត់ក្តី ឬ អំពីអ្នកឯទៀតណាក៏ដោយ ។

២ : ក្រុមចៅក្រមមិនត្រូវនៅក្រោមចំណុះអំណាចនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិ ឬ ក្រោមភាគីនយោបាយណាឡើយ។ ជនដែលត្រូវគេជ្រើសរើសអោយបំពេញមុខងារក្នុងតុលាការ ត្រូវតែជាអ្នកសុចរិត និងមានសមត្ថភាពផង ។

៣ : គោលការណ៍ឯករាជភាពនៃក្រុមចៅក្រមប្រគល់សិទ្ធិ និងករណីយកិច្ចជូនចៅក្រម ដើម្បីធានាអោយការកាត់ក្តីប្រព្រឹត្តទៅក្នុងភាពសុចរិត និង ក្នុងការគោរពដល់សិទ្ធិនៃភាគីដែលត្រូវកាត់ក្តីទាំងអស់ ។ ចៅក្រមត្រូវមានលទ្ធភាពបំពេញមុខងារខ្លួនតាមស្ថានភាពសម្ភារៈសមរម្យ និង គ្រប់គ្រាន់ ។ ចៅក្រមត្រូវទទួលការហ្វឹកហាត់ត្រឹមត្រូវ មានប្រាក់បៀវត្សគ្រប់គ្រាន់ ដើម្បីធានានូវភាពឥតលំអៀង និង ឯករាជភាពរបស់ពួកគេ ។

## មាត្រា ២ : មុខងារនៃតុលាការ

សមាសភាពនៃក្រុមចៅក្រមមាន ចៅក្រម និង រដ្ឋអាជ្ញា ។ មានតែចៅក្រមទេដែលមានអំណាចសម្រេចសេចក្តី ។ រដ្ឋអាជ្ញាមានបន្ទុកខាងបណ្តឹងអាជ្ញាព្រហ្មទណ្ឌ ដែលមានតែរដ្ឋអាជ្ញាទេដែលមានអំណាចធ្វើកិច្ចការហ្នឹង ។ រដ្ឋអាជ្ញាជាអ្នករៀបចំសំណុំពាក្យចោទប្រកាន់ សំរាប់ដាក់ជូនតុលាការជំនុំជំរះ និងដាក់ជូនអង្គប្រជុំផ្សេងៗទៀត ដែលមានចែងនៅក្នុងបទបញ្ញត្តិនេះ ។ម្យ៉ាងវិញទៀត អគ្គរដ្ឋអាជ្ញាជាអ្នកលើកយកសំណុំពាក្យចោទប្រកាន់ដាក់ជូនតុលាការកំពូល ក្នុង [illegible] របស់រដ្ឋអាជ្ញាទេ តាមតែង និងការពារកិច្ចការរបស់រដ្ឋអាជ្ញា ។

## មាត្រា ៣ : សាលាជំរះក្តី

១ : ដោយមានសហការជាមួយអ៊ុនតាក់ ភាគីកម្ពុជាទាំងអស់សន្យាថានឹងចាត់ចែងអោយមានសាលាដំបូងមួយ យ៉ាងតិច នៅក្នុងតំបន់ ឬខេត្តណាដែលខ្លួនមិនទាន់បានចាត់តាំង ។ ចៅក្រមនានានឹងត្រូវរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃតែងតាំងឡើង. តម្លើងឋានន្តរស័ក្តិ ឬបញ្ឈប់ពីតំណែង ក្រោមកិច្ចត្រួតពិនិត្យរបស់អ៊ុនតាក់ ។

២ : សាលាដំបូងត្រូវមានចៅក្រមម្នាក់ និង រដ្ឋអាជ្ញាម្នាក់ ។ សាលាកាត់ក្តីទាំងនេះមានសមត្ថកិច្ចទាំងស្រុងក្នុងការអនុវត្តន៍បទបញ្ញត្តិបច្ចុប្បន្ននេះ ព្រមទាំងមានសមត្ថកិច្ចលើច្បាប់ ឬបទដ្ឋានទាំងឡាយឯទៀតៗជាធរមាន តាមយុត្តាធិការរៀងៗខ្លួន ។

៣ : ចៅក្រមជំនួស អាចត្រូវគេតែងតាំងក្នុងលក្ខខ័ណ្ឌដូចគ្នានឹងចៅក្រមដែរ ដើម្បីជំនួសចៅក្រមដែលសុំដកខ្លួនពីការជំនុំជំរះ ក្នុងករណីណាដែលមានទំនាស់ខាងផលប្រយោជន៍ ឬក្នុងករណីអសមត្ថភាព ។

## មាត្រា ៤ : សាលាឧទ្ធរណ៍

១ : ដោយសហការណ៍ជាមួយអ៊ុនតាក់ ភាគីទាំងឡាយសន្យាថានឹងចាត់ចែងអោយមានសាលាឧទ្ធរណ៍មួយ យ៉ាងតិច នៅក្នុងតំបន់ ឬដែនដីណាដែលខ្លួនមិនទាន់បានបង្កើតនៅឡើយ ។ ចៅក្រមទាំងឡាយនឹងត្រូវរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃតែងតាំង. តម្លើងឋានន្តរស័ក្តិ ឬបញ្ឈប់ពីតំណែង ក្រោមកិច្ចត្រួតពិនិត្យរបស់អ៊ុនតាក់ ។

២ : សាលាឧទ្ធរណ៍នេះមានចៅក្រមបីនាក់ និង រដ្ឋអាជ្ញាម្នាក់ ដែលតែងតាំងឡើងដោយរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ក្រោមកិច្ចត្រួតពិនិត្យរបស់ អ៊ុនតាក់ ។ ចៅក្រមជំនួសអាចត្រូវគេតែងតាំងក្នុងលក្ខខ័ណ្ឌដូចគ្នា ដើម្បីជំនួសចៅក្រមណាដែលសុំដកខ្លួនពីការជំនុំជំរះ ក្នុងករណីណាដែលមានទំនាស់ខាងផលប្រយោជន៍ ឬ ក្នុងករណីអសមត្ថភាព ។

៣ : បណ្តាភាគីដែលមានទាក់ទិនក្នុងរឿងក្តីនេះ: ភាគីរដ្ឋប្បវេណី, ទណ្ឌិត ឬទីប្រឹក្សារបស់ភាគីទាំងសងខាង, រដ្ឋអាជ្ញាអាចប្តឹងឧទ្ធរណ៍ពីសេចក្តីសំរេចរបស់សាលាដំបូងនានា ក្នុងរយៈពេល ២ ខែ ចាប់ពីថ្ងៃដែលចៅក្រមប្រកាសសាលក្រមនោះ បើសិនជាសាលក្រមនោះធ្វើឡើងចំពោះមុខសាមីខ្លួន, ហើយបន្ថែមពេលបណ្តឹងជំទាស់ ១៥ ថ្ងៃថែមទៀត បើការកាត់ទោសនេះធ្វើឡើងដោយគ្មានសាមីខ្លួន ។ សាលក្រមចំពោះមុខ គឺធ្វើឡើងដោយមានវត្តមានជនជាប់ចោទក្នុងពេលជំនុំជំរះ ពុំនោះសោតទេ និងទុកដូចជាការកាត់ក្តីមិនចំពោះមុខ ។

៤ : សាលាឧទ្ធរណ៍ជំនុំជំរះទាំងអង្គច្បាប់ ទាំងអង្គហេតុ ។

## មាត្រា ៥ : តុលាការជាន់ខ្ពស់

ដោយអនុលោមតាមសំណូមពររបស់ភាគី «រដ្ឋកម្ពុជា» ដំណើរការនៃតុលាការជាន់ខ្ពស់បច្ចុប្បន្ននិងត្រូវកែលំអ ដើម្បីអោយមានលទ្ធភាពគោរពតាមកាតព្វកិច្ច ដែលចែងក្នុងមាត្រា ១ ព្រមទាំងបំពេញមុខងារដូចខាងក្រោមនេះ ៖

ក- តុលាការនេះជាតុលាការជំនុំជំរះអង្គច្បាប់

ខ- តុលាការនេះអាចទទួលពាក្យបណ្តឹងកែតម្រូវចំពោះសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ ពីរដ្ឋអាជ្ញា, ជនជាប់ទោស, ភាគីរដ្ឋប្បវេណី ឬ ទីប្រឹក្សារបស់គេ ក្នុងរយៈពេលពីរខែ ចាប់ពីថ្ងៃដែលចេញសាលដីកាជំនុំជំរះ បើសាលដីកានោះធ្វើឡើងចំពោះមុខ ហើយនិង បន្ថែមពេលបណ្តឹងជំទាស់ ១៥ ថ្ងៃថែមទៀត បើសាលដីកានេះធ្វើឡើងដោយមិនចំពោះមុខ ។ សាលដីកាចំពោះមុខ គឺធ្វើឡើងដោយមានវត្តមានជនជាប់ចោទក្នុងពេលជំនុំជំរះ ពុំនោះទេនិងទុកដូចជាមិនចំពោះមុខ ។

គ- តុលាការនេះអាចបញ្ជូនសំណុំរឿងទាំងឡាយត្រឡប់ទៅសាលាឧទ្ធរណ៍មួយដែលមានសមាសភាពផ្សេងខុសពីមុន ហើយបើសាលាឧទ្ធរណ៍ថ្មីនេះមិនសម្រេចតាមសាលដីកាខ្លួនទេនោះ តុលាការនេះអាចទទួលបណ្តឹងពីរដ្ឋអាជ្ញា ទណ្ឌិត ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់គេ ក្នុងរយៈពេលពីរខែ ចាប់ពីថ្ងៃដែលប្រកាសសាលដីកា ក្នុងល័ក្ខខ័ណ្ឌដែលដូចបានចែងនៅក្នុងវគ្គ ខ នៃមាត្រានេះ ។ ពេលនោះ តុលាការជាន់ខ្ពស់អាចជំនុំជំរះទាំងអង្គហេតុ និងទាំងអង្គច្បាប់ ហើយធ្វើសេចក្តីសំរេចជាស្ថាពរតែម្តង ។

## មាត្រា ៦ : នគរបាល

១ : នគរបាលត្រូវប្រតិបត្តិតាម *បទបញ្ញាសីលធម៌សំរាប់អ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់* ហើយបើអាចធ្វើទៅបាន ត្រូវប្រតិបត្តិតាម *គោលច្បាប់ជាមូលដ្ឋានស្តីអំពីការប្រើកម្លាំង និងការប្រើកាំភ្លើងនៃអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

២ : បណ្តាភាគី ដែលកងកំលាំងរបៀបរៀបរយរបស់ខ្លួនមិនមានលទ្ធភាពបំពេញតាមការតម្រូវនៃបទបញ្ញត្តិនេះ សន្យាសហការជាមួយអ៊ុនតាក់ ដើម្បីរៀបចំអោយមាន និង បង្ហាត់ហ្វឹកហ្វឺនកងកំលាំងនគរបាលមួយអោយបានត្រឹមត្រូវ ។

## មាត្រា ៧ : មេធាវី និង ទីប្រឹក្សា

១ : មេធាវីទាំងឡាយនឹងត្រូវអនុញ្ញាតអោយបង្កើតជាអង្គការមេធាវី ដែលមានរូបភាពជាសមាគមមួយ ដោយមានអំណាចខាងវិន័យ និងបទបញ្ជាទៅលើសមាជិកខ្លួនទាំងអស់ ។ អង្គការមេធាវីមិនត្រូវទទួលការបង្គាប់បញ្ជា ពាក់ព័ន្ធខាង ពីគណៈបក្សនយោបាយណាមួយ ពីស្ថាប័នអំណាចនីតិបញ្ញត្តិណាមួយ ឬ ពីស្ថាប័នអំណាចនីតិប្រតិបត្តិណាមួយ ដែលនៅក្រោមដឹកនាំនៃភាគីកម្ពុជាណាមួយ ក្នុងកិច្ចព្រមព្រៀងប៉ារីស ។

ក្នុងរយៈពេលអន្តរកាល ជនដែលអាចធ្វើជាមេធាវីបាន គឺជនទាំងឡាយណាដែល យ៉ាងហោចណាស់ មានសញ្ញាប័ត្រស្មើនឹងបរិញ្ញាប័ត្រនីតិសាស្ត្រ ឬមានការពិសោធន៍ប្រាំឆ្នាំក្នុងវិស័យច្បាប់ ឬ វិស័យតុលាការ ប្រកបដោយការខ្ពស់ទទួលខុសត្រូវក្នុងកិច្ចការបាន ។

២ : ដោយចំនួនមេធាវីមានតិចតួចពេកនៅប្រទេសកម្ពុជា ក្នុងរយៈពេលអន្តរកាលនេះ ជនកម្ពុជាគ្រប់រូបដែលមានសញ្ញាប័ត្រមធ្យមសិក្សា អាចតំណាងជនជាប់ចោទនៅចំពោះមុខតុលាការបាន ល្គឹកណាដែលអ្នកនោះគ្មានមានតួនាទីជាអ្នកដឹកនាំក្នុងបណ្តាញដឹកនាំ ជាអ្នកជាប់ឆ្នោតក្នុងរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ឬក្នុងគណៈបក្សនយោបាយដែលគេទទួលស្គាល់ទាំងឡាយ ។ លើសពីនោះទៀត ជនជាប់ចោទអាចពឹងពាក់សមាជិកគ្រួសារខ្លួន អោយធ្វើជាជំនួយការពារខ្លួនបាន ទោះបីមានការសិក្សាថ្នាក់ណាក៏ដោយ ។

៣ : នៅចំពោះមុខតុលាការ អ្នកតំណាងជនជាប់ចោទមានសិទ្ធិដូចជាមេធាវីដែរ ក្នុងការជូនដំណឹងពីឯកសារ ក្នុងការធ្វើលិខិតនីតិវិធី ឬ ក្នុងការជជែកការពារជនជាប់ចោទ ។ ក្នុងបទបញ្ញត្តិនេះ ពាក្យថា «ទីប្រឹក្សា» មានន័យមិនខុសពីពាក្យមេធាវី ឬ អ្នកតំណាងគ្រប់ប្រភេទរបស់ជនជាប់ចោទឡើយ ។

៤ : មេធាវីបរទេសអាចជជែកការពារចំពោះតុលាការកម្ពុជា ក្នុងកាលៈទេសៈណាដែលគេអាចបង្ហាញភស្តុតាងថា គេបានចុះឈ្មោះក្នុងអង្គការមេធាវីមួយ ឬ ក៏គេបានសេចក្តីអនុញ្ញាតជាផ្លូវការអោយជជែកការពារនៅក្នុងប្រទេសរបស់គេ ។ រដ្ឋាភិបាលដែលមានសព្វថ្ងៃសន្យាថានឹងជួយសម្រួលក្នុងការផ្តល់ទិដ្ឋាការចូល ដល់មេធាវីដែលមកបំពេញការងារនៅក្នុងប្រទេសកម្ពុជា ។

## មាត្រាទី ៨ : ប្រព័ន្ធពន្ធនាគារ

១ : ប្រព័ន្ធពន្ធនាគារមានគោលដៅធ្វើអោយមាននិតិសម្បទាសង្គមឡើងវិញ ។ ការប្រព្រឹត្តិចំពោះអ្នកជាប់ទោស ត្រូវតែស្របទៅតាម *បទដ្ឋានអប្បបរិមានៃបទវិន័យសំរាប់គ្រប់គ្រងអ្នកទោស* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

២ : [illegible] ចាប់ឃាត់ឃាំងជនជាប់សង្ស័យ ឬឃុំឃាំងមនុស្សក្នុងពេលមុន ឬក្រោយការកាត់ទោស ត្រូវមានបញ្ជីតុកដែលមានវេជ្ជបញ្ជា និង ចៅក្រមម្នាក់ប្រចាំខេត្ត ឬតំបន់ចុះហត្ថលេខាគ្រប់ខែ ដើម្បីពិនិត្យបញ្ជាក់ឈ្មោះ អាយុ. អាស័យដ្ឋាន. ថ្ងៃ ខែ ឆ្នាំ និងមូលហេតុនៃការចាប់ខ្លួន. ថ្ងៃ ខែ ឆ្នាំដែលបានបញ្ជូនខ្លួនទៅចៅក្រម. ហើយនិងថ្ងៃ ខែ ឆ្នាំដែលត្រូវគេកាត់ទោស និងទោសដែលគេបានកាត់ហើយ ចំពោះទណ្ឌិត ។

## មាត្រា ៩ : ការពិនិត្យកន្លែងឃុំឃាំង

១- វេជ្ជបញ្ជា ឬ ចៅក្រមទាំងឡាយអាចចូលពិនិត្យពន្ធនាគារ និងអ្នកទោសបានគ្រប់ពេលវេលា ។

២- ភ្នាក់ងារដែលអនុញ្ញាតដោយផ្នែកសិទ្ធិមនុស្ស រដ្ឋបាលស៊ីវិល និង ប៉ូលិសរបស់អ៊ុនតាក់ ក៏មានសិទ្ធិដូចគ្នាដែរ ។ ក្នុងរឿងនេះ ភាគីខ្មែរទាំងអស់នៃកិច្ចព្រមព្រៀងប៉ារីស ត្រូវធ្វើបញ្ជីរាយទីកន្លែងឃុំឃាំងរបស់ខ្លួនទាំងអស់ អោយបានយ៉ាងយឺតបំផុតនៅពេលដែលបទបញ្ញត្តិនេះចូលជាធរមាន ហើយបញ្ជូនបញ្ជីនេះទៅទីចាត់ការកណ្ដាលនៃផ្នែករដ្ឋបាលស៊ីវិលរបស់អ៊ុនតាក់ ។

# មេរៀនទី ៥ នីតិវិធីច្បាប់

## ១-ជំនួយផ្នែកច្បាប់ :

### មាត្រា ១០ : ជំនួយផ្នែកច្បាប់

១ : សិទ្ធិពឹងពាក់មេធាវី ឬទីប្រឹក្សា ត្រូវបានធានាជូនជនគ្រប់រូបដែលជាប់ចោទពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ ។

២ : ទោះបីបទល្មើសនោះធ្ងន់ស្រាលយ៉ាងណាក៏ដោយ គ្មានជនណាម្នាក់ត្រូវជាប់ឃុំឃាំង នៅលើទឹកដីកម្ពុជា លើសពីរយៈពេល ៤៨ម៉ោង ដោយគ្មានបានទទួលជំនួយពីទីប្រឹក្សា ពីមេធាវី ឬ ពីអ្នកតំណាង ដែលបទបញ្ញត្តិនេះបានអនុញ្ញាតឡើយ ។

### មាត្រា ១១ : តុលាការយោធា

តុលាការយោធាទទួលជំនុំជំរះតែបទល្មើសយោធាទេ។ បទល្មើសយោធា គឺជាបទល្មើសដែលទាក់ទិនដល់យោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលពាក់ព័ន្ធដល់បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា ។ បទឧក្រិដ្ឋ ឬ បទល្មើសនិងច្បាប់សាមញ្ញ ដែលប្រព្រឹត្តដោយយោធិន និងត្រូវទទួលការជំនុំជំរះនៅតុលាការស៊ីវិល ។

## មាត្រា ១២ : ការគ្រប់គ្រងជនជាប់ឃុំ

១ : គ្មានជនជាប់ឃុំណាម្នាក់ត្រូវទទួលទណ្ឌកម្ម ឬ ការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬនាំអោយបាត់បង់តម្លៃជាមនុស្ស ឬក៏ត្រូវគេវាយដំ និង ធ្វើទារុណកម្មឡើយ ។ ជនជាប់ឃុំម្នាក់ៗត្រូវបានទទួលការថែទាំតាមវិធីពេទ្យត្រឹមត្រូវ ។ អ្នកទោសទាំងឡាយមិនត្រូវបានគេចង ឬ ដាក់អោយនៅឯកោម្នាក់ឯង ទោះស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នក្តី ឬត្រូវបានកាត់ទោសរួចហើយក្តី ។ ទោះក្នុងករណីណាក៏ដោយ គ្រួសារអ្នកជាប់ឃុំ ឬគ្រួសារអ្នកទោសមិនត្រូវមានគេយាយី ដោយសារតែការប្រព្រឹត្តិរបស់ជននោះឡើយ ។

២ : ការចាប់ខ្លួន និងការឃុំខ្លួនត្រូវតែគោរពតាម *បទដ្ឋានអប្បបរិមានៃបទវិន័យសំរាប់គ្រប់គ្រងអ្នកជាប់ឃុំ* ព្រមទាំងត្រូវគោរពតាម *គោលការណ៍ជាមូលដ្ឋានសំរាប់ការពារអ្នកទោស* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

## មាត្រាទី ១៣ : ការចាប់ខ្លួន និង ការឃុំខ្លួន

១ : គ្មានជនណាម្នាក់ត្រូវបានគេឃុំខ្លួនលើសពី ៤៨ម៉ោង ដោយមិនបានបញ្ជូនទៅចៅក្រម តាមរយៈបណ្តឹងរបស់រដ្ឋអាជ្ញាឡើយ ។ ក្នុងករណីណាដែលពុំអាចគោរពតាមបិវេលានេះបាន ដោយសារស្ថានភាពនៃការដឹកជញ្ជូនក្នុងតំបន់និមួយៗនោះ គេអាចបន្ថែមបាននូវពេលវេលាចាំបាច់សំរាប់តែដឹកនាំអ្នកជាប់ឃុំយ៉ាងនេះ ទៅជូនចៅក្រមតាមមធ្យោបាយយ៉ាងឆាប់ដែលអាចធ្វើបាន ។

២ : រដ្ឋអាជ្ញាសុំអោយចៅក្រមចោទប្រកាន់ ព្រមទាំង ជាយថាហេតុ ឃុំខ្លួនជនជាប់សង្ស័យ ក្រោយពីបានពិនិត្យសំណុំរឿងពីនគរបាល ដោយរៀបរៀងដីកាសន្និដ្ឋានមួយ ទុកជាសេចក្តីផ្តើមចោទ យោងតាមអង្គហេតុជាក់ស្តែង និងដែលកំណត់បទល្មើសតាមច្បាប់អោយស្របទៅតាមបទបញ្ញត្តិក្រមព្រហ្មទណ្ឌនេះ ។

៣ : ក្នុងខណៈនោះ ដោយផ្អែកលើសេចក្តីសំរេចដែលមានចែងមូលហេតុ ចៅក្រមអាចសំរេចថា ៖

- ត្រូវចោទប្រកាន់ជនជាប់សង្ស័យ ដោយអោយឃុំឃាំង ឬ មិនអោយឃុំឃាំង
- អោយដោះលែងជនជាប់សង្ស័យ ដោយចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពមិនគ្រប់គ្រាន់

- សំរេចអោយបន្តការស៊ើបអង្កេត ដោយមិនប្រាប់ឈ្មោះជនជាប់សង្ស័យ ។

៤ : ក្នុងរយៈពេលយ៉ាងច្រើន ៤៨ម៉ោងដូចគ្នានេះ ក្រោយការចាប់ខ្លួន ហើយ ជាយថាហេតុ ត្រូវបានពន្យារយៈវេលាចាំបាច់ក្នុងការដឹកនាំ ដូចបានចែងនៅវគ្គទី១ ទីប្រឹក្សាត្រូវបានទទួលសំណុំរឿង ដែលទាក់ទងក្នុងការចោទប្រកាន់ចំពោះជនជាប់សង្ស័យ ។

✓ <u>មាត្រាទី ១៤ : ការឃុំខ្លួនជាបណ្តោះអាសន្ន</u>

១ : មានតែចៅក្រមទេ ដែលអាចសម្រេច ដោយមានចែងមូលហេតុ អោយឃុំខ្លួនជនជាប់ចោទទុកក្នុងមន្ទីរឃុំឃាំងតាមសេចក្តីស្នើសុំរបស់រដ្ឋអាជ្ញា ហើយមានតែក្នុងករណីដែលបារម្ភខ្លាចក្រែងជននោះរត់គេចខ្លួន និងដោយគ្មានអ្វីអាចអោយធានាបានថា ជនជាប់ចោទប្រាកដជាត្រឡប់មកបង្ហាញខ្លួនចំពោះមុខតុលាការវិញ មានន័យថា សាមីជនគ្មានការងារធ្វើ គ្មានគ្រួសារ គ្មានទីលំនៅពិតប្រាកដ ឬដោយខ្លាចជនជាប់ចោទនោះប្រើឥទ្ធិពលលើសាក្សី ឬលើដំណើរការស៊ើបអង្កេត ។

២ : ជនជាប់ចោទមានសិទ្ធិសុំចៅក្រម អោយដោះលែងខ្លួន តាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈទីប្រឹក្សារបស់ខ្លួន ។ ក្នុងរយៈពេលប្រាំថ្ងៃ ចៅក្រមត្រូវឆ្លើយតាមដីកាដែលមានចែងមូលហេតុ ។

៣ : ក្នុងរយៈពេល៥ថ្ងៃក្រោយពីដីកានោះមក ជនជាប់ចោទ, ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់ភាគីទាំងសងខាង ឬរដ្ឋអាជ្ញាអាចសុំឧទ្ធរណ៍ពីសេចក្តីសំរេចរបស់ចៅក្រម ។ ក្នុងរយៈពេល១៥ថ្ងៃ សាលាឧទ្ធរណ៍ត្រូវសំរេចលើពាក្យសុំឧទ្ធរណ៍ទាំងឡាយដែលទាក់ទិនក្នុងរឿងឃុំខ្លួននេះ ។

៤ : រយៈពេលឃុំឃាំងជាបណ្តោះអាសន្ន ទោះស្ថិតក្នុងករណីណាក៏ដោយ មិនត្រូវអោយហួសពីបួនខែទេ ។ ប៉ុន្តែតាមការសំរេច ដែលមានចែងមូលហេតុរបស់ចៅក្រម រយៈពេលនេះអាចបន្តដល់ប្រាំមួយខែ ប្រសិនបើមានការចាំបាច់សំរាប់ធ្វើការស៊ើបអង្កេត ។

៥ : អនីតិជនអាយុតិចជាង ១៣ឆ្នាំមិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នទេ ។ អនីតិជនដែលមានអាយុ ១៣ ទៅ ១៨ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នលើសពី ១ខែទេ ។ រយៈពេលនេះអាចទ្វេឡើងជាពីរ បើសិនជាមានការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ ។

## មាត្រា ១៥ : ការឃុំខ្លួនតាមបទរដ្ឋបាល

នៅប្រទេសកម្ពុជាមិនត្រូវមានជនណាត្រូវឃុំឃាំង ដោយនគរបាលរដ្ឋបាលណាមួយ ឬ ពីបទល្មើសណាដែលគ្មានចែងនៅក្នុងបទបញ្ញត្តិនេះ ឬ ក្នុងច្បាប់ឯទៀត ឬអត្ថបទឯទៀតៗខាងវិស័យព្រហ្មទណ្ឌឡើយ ។

## មាត្រា ១៦ : ការដោះលែងជនជាប់ឃុំ

ជនដែលជាប់ឃុំឃាំង ឬឃាត់ខ្លួនទុកនៅតាមមន្ទីរឃុំឃាំងនានា ដែលគ្មានឈ្មោះក្នុងបញ្ជីដូចមានរៀបរាប់នៅក្នុងមាត្រា ៩ នៃបទបញ្ញត្តិនេះ នឹងត្រូវចាត់ទុកថាបានជាប់ឃុំឃាំងខុសច្បាប់ ហើយត្រូវតែដោះលែងភ្លាមមួយរំពេច តាមសេចក្តីសុំរបស់រដ្ឋអាជ្ញា, ក្រប់សាលាដំបូង, ទីប្រឹក្សារបស់អ្នកជាប់ឃុំ ឬបុគ្គលិកដែលមានសេចក្តីអនុញ្ញាតពីផ្នែករដ្ឋបាលស៊ីវិលរបស់អ៊ុនតាក់, ផ្នែកសិទ្ធិមនុស្ស និង នគរបាលស៊ីវិលរបស់អ៊ុនតាក់ ។ ឯអ្នកដែលត្រូវគេឃុំឃាំង ឬឃាត់ខ្លួនទុកនៅក្នុងមន្ទីរឃុំឃាំងដែលបានប្រកាស ហើយដែលគ្មានឈ្មោះលើបញ្ជីឃុំឃាំង ក៏ត្រូវតែដោះលែងដូចគ្នាដែរ ។

## មាត្រា ១៧ : សិទ្ធិពិនិត្យសំណុំរឿង

១ : ប្រសិនបើចៅក្រមសំរេចថា ចាំបាច់ត្រូវស៊ើបអង្កេតបន្ថែមទៀត, តាមលំដាប់លំដោយនៃការស៊ើបអង្កេតនេះ, ទីប្រឹក្សារបស់ជនជាប់ចោទត្រូវតែបានទទួលដំណឹងជាបន្ទាន់ អំពីភ័ស្តុតាងថ្មីៗទៀត ប្រឆាំងនឹងកូនក្តីរបស់ខ្លួន ។

២ : ទីប្រឹក្សាមានសិទ្ធិពិនិត្យសំណុំរឿងអ្នកជាប់ចោទ ដោយគ្រាន់តែស្នើសុំជាលាយលក្ខអក្សរ នៅគ្រប់ដំណាក់កាលនៃនីតិវិធី ហើយអាចទទួលបានពីចៅក្រម នូវគ្រប់លទ្ធផលដែលបានមកអំពីការស៊ើបអង្កេត, អំពីសេចក្តីរាយការណ៍របស់អ្នកជំនាញការ ឬអំពីសវនកម្មដែលខ្លួនយល់ថា មានប្រយោជន៍ក្នុងការការពារកូនក្តីរបស់ខ្លួន ។

## ✓ មាត្រា ១៨ : បទល្មើសជាក់ស្តែង

នគរបាលអាចចាប់ខ្លួនជនណាដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង គឺជា ៖

- បើជនសង្ស័យត្រូវគេឃើញទាន់ពេលកំពុងតែប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ឬប្រសិនបើកំពុងត្រូវគេស្រែកដេញប្រជាប់ចាប់ប្រកិង
- បើជនសង្ស័យត្រូវបានសាក្សី ឬ អ្នករងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ បទល្មើស ថាជាពិរុទ្ធជន
- បើជនសង្ស័យកំពុងរកវិធីរត់ចេញពីកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ។

## ✓ មាត្រា ១៩ : ការចាប់ខ្លួនដោយសំអាងលើភស្តុតាងជាក់ស្តែងយ៉ាងធ្ងន់

១ : ក្នុងករណីផ្សេងទៀតទាំងអស់ នគរបាលតុលាការអាចចាប់ខ្លួនជនជាប់សង្ស័យបាន លុះត្រាតែមានភស្តុតាងជាក់ស្តែងយ៉ាងខ្លាំង ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលបង្ហាញអោយឃើញថា ជននោះបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមមែន ។

២ : បើជនជាប់សង្ស័យលួចរត់គេចខ្លួន ជននោះអាចត្រូវចាប់ខ្លួនបាន តាមដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញា ឬ ចៅក្រម ដែលនឹងគេអនុវត្តដោយនគរបាលតុលាការ ។

៣ : ដីកាចាប់ខ្លួនត្រូវមានបញ្ជាក់អំពីអំពើ និងមូលហេតុទាំងឡាយ ដែលនាំអោយមានការចាប់ខ្លួនជនជាប់សង្ស័យនោះ ។

៤ : ជោគវាសនារបស់ជនដែលត្រូវគេចាប់ខ្លួន ត្រូវបានចាត់ចែង តាមលក្ខន្តិកៈនៅក្នុងមាត្រា១៣ នៃបទបញ្ញត្តិនេះ ។

៥ : ម្យ៉ាងទៀត តាមដីកាបង្គាប់អោយទៀងសាលារបស់រដ្ឋអាជ្ញា ឬ ចៅក្រម នគរបាលអាចនាំខ្លួនជនគ្រប់រូប ដែលមានប្រយោជន៍ក្នុងការស៊ើបអង្កេត ហើយដែលប្រកែកមិនព្រមចូលខ្លួនតាមដីកានោះ មកបង្ហាញខ្លួនចំពោះមុខនាយនគរបាល ឬចៅក្រម ឬរដ្ឋអាជ្ញា។ ក្រោយពីតុលាការបានសាកសួរហើយ ជននោះត្រូវបានដោះលែងជាបន្ទាន់ លើកលែងតែក្នុងករណីមានភស្តុតាងជាក់ស្តែងយ៉ាងធ្ងន់ ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលត្រូវអនុវត្តតាមនីតិវិធីនៃមាត្រាទី ១៣ នៃបទបញ្ញត្តិនេះ ។

## មាត្រា ២០ : ការឆែកឆេរក្នុងផ្ទះ

១ : ក្នុងករណីបទល្មើសជាក់ស្តែង នគរបាលអាចធ្វើការឆែកឆេរ ។

២ : ការឆែកឆេរទាំងនេះត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងសាក្សីពីរនាក់ ហើយបើអាចធ្វើបាន សាក្សី គួរយកអ្នកនៅជិតខាង ឬ អ្នកម្ចាស់ផ្ទះ ។

៣ : បើមិនមែនជាបទល្មើសដែលគេទាន់ជាក់ស្តែងទេ ការរឹបអូសទាំងឡាយត្រូវមានសេចក្តីអនុញ្ញាតអំពីចៅក្រមណាមួយនៃតុលាការពាក់ព័ន្ធ ឬ ពីរដ្ឋអាជ្ញា ។ ការឆែកឆេរទាំងនេះអាចធ្វើបានតែក្នុងចន្លោះម៉ោង ៦ ព្រឹក ទៅម៉ោង ៦ ល្ងាច ។ ហើយបើអាចធ្វើបាន ការឆែកឆេរទាំងនេះត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងចំពោះមុខសាក្សីពីរនាក់ ដែលជ្រើសយកពីក្នុងចំណោមសមាជិកគ្រួសារជនជាប់សង្ស័យ ។ ភស្តុតាងទាំងឡាយណា ដែលបានមកដោយរំលោភនឹងមាត្រានេះ មិនអាចយកជាការបានទៀយ ក្នុងពិធីកាត់សេចក្តី ។

## មាត្រា ២១ : កំណត់ពេល

១ : គ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តី ត្រូវតែបានទទួលការកាត់ក្តី យ៉ាងយូរបំផុតប្រាំមួយខែ ក្រោយពីថ្ងៃចាប់ខ្លួន ។

២ : ទីប្រឹក្សា ឬ មេធាវីត្រូវបានទទួលដំណឹង ១៥ ថ្ងៃ មុនថ្ងៃជំនុំជំរះក្តីខ្លួន -

## មាត្រា ២២ : ការដោះលែងដោយមូលហេតុខុសនីតិវិធី

១ : ការមិនបានគោរពតាមនីតិវិធីដែលចែងក្នុងមាត្រា ១០ ទៅមាត្រា ២១ នាំឲ្យដោះលែងជនជាប់ចោទ អោយមានសេរីភាពជាបន្ទាន់ ប្រសិនបើការខុសឆ្គងនោះ ធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិនៃការការពារ ។ ការប្រគល់សេរីភាពជាបន្ទាន់នេះ អាចធ្វើឡើងតាមសេចក្តីសុំរបស់ទីប្រឹក្សានៃជនជាប់ចោទ ឬមន្ត្រីដែលមានការអនុញ្ញាតនៃផ្នែករដ្ឋបាលស៊ីវិល ផ្នែកសិទ្ធិមនុស្ស ឬ ផ្នែកនគរបាលស៊ីវិលរបស់អ៊ុនតាក់ ។ ដល់ថ្ងៃដែលបទបញ្ញត្តិនេះបានចូលជាធរមាន ជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារទាំងអស់ ត្រូវមានសំណុំរឿងសមស្របតាមលក្ខខណ្ឌនៃបទបញ្ញត្តិនេះ សំរាប់ត្រួតពិនិត្យជាបន្ទាន់ពីសំណាក់ចៅក្រម រដ្ឋអាជ្ញា ឬ [illegible] ដែលមានការអនុញ្ញាតរបស់អ៊ុនតាក់ ។ [illegible]

ដោះលែងអោយមានសេរីភាព តាមសេចក្តីសុំរបស់ទីប្រឹក្សា. មន្ត្រីដែលមានការអនុញ្ញាតនៃផ្នែករដ្ឋបាលស៊ីវិល, ផ្នែកសិទ្ធិមនុស្ស ឬ ផ្នែកនគរបាលស៊ីវិលរបស់អ៊ុនតាក់ ចៅក្រម ឬ រដ្ឋអាជ្ញា ។

២ : ការរំលោភ ពីសំណាក់ភ្នាក់ងារសាធារណៈ លើសិទ្ធិបុគ្គល ដូចមានចែងក្នុងមាត្រា ១០ ទៅមាត្រា ២១ នៃបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសតាមមាត្រា ៥៧ ។

## ២ វិធីកាត់ក្តី :

### មាត្រា ២៣ : ការជំនុំជំរះជាអសាធារណៈ

ការកាត់ក្តីទាំងអស់ត្រូវតែធ្វើជាសាធារណៈ លើកលែងតែរឿងការងក្រោះ ឬ សិទ្ធិវន្តរបស់គេស្នើសុំអោយជំនុំជំរះជាអសាធារណៈ ហើយចៅក្រមយល់ព្រមផង ។

### មាត្រា ២៤ : មធ្យោបាយបង្ហាញភស្តុតាង

១ : សាក្សីទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿង ព្រមទាំងបន្ទាល់ [illegible] ត្រូវតែ បាននិយាយជូនតុលាការស្តាប់ ។ សាក្សីទាំងឡាយអាចត្រូវសួរដោយផ្ទាល់ [illegible] ភាគីរដ្ឋប្បវេណី ឬមេធាវីការពាររបស់គេ ជនជាប់ចោទ ឬ មេធាវីការពាររបស់គេ ហើយនិង [illegible] ជំនាញ ។

២ : ភស្តុតាងទាំងអស់អាចលើកមកជជែកតែក្នុងពេលជំនុំជំរះ [illegible] របាយការណ៍នគរបាលផង ដែលមិនអាចចាត់ទុកថាជាភស្តុតាងដែលត្រូវគេ [illegible] នោះទេ ។

៣ : បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយ ដែលមិន [illegible] ដើមកំណើតនៃភស្តុតាងទេនោះ ទោះក្នុងករណីណាក៏ដោយ មិនអាចទុកជាមូលដ្ឋាន [illegible] ទោសបានទៀយ ។ ពាក្យសារភាពដែលបានមកអំពីការបង្ខិតបង្ខំ តាមបែបណាមួយក៏ដោយ ត្រូវទុកជាមោឃៈ ។ ការសុំទុកជាមោឃៈនេះត្រូវស្នើសុំទៅចៅក្រម ដោយមេធាវីការពាររបស់ជនជាប់ចោទ នៅមុនពេលកាត់ក្តី ។

: អ្នកការពារចុងចោទអាចយកសាក្សីខ្លួនមកបង្ហាញតុលាការ ហើយអាចជូនភស្តុតាងខ្លួនទៅតុលាការ ។

៥ : សាក្សីទាំងអស់ ទាំងខាងដើមចោទ ទាំងខាងចុងចោទ អាចទទួលការបង្ខំអោយបង្ហាញខ្លួនចំពោះមុខតុលាការ តាមរយៈដីកាតាំខ្លួនរបស់តុលាការ ដោយត្រូវពិន័យជាប្រាក់ពី ១០០,០០០ ទៅ ១,០០០,០០០ រៀល បើមិនព្រមប្រព្រឹត្តតាម ។

## មាត្រា ២៥ : ការសន្មត់ជាមុនថាគ្មានទោស

គ្រប់ជនដែលគេសង្ស័យ គ្រប់ជនជាប់ពិរុទ្ធ គ្រប់ជនជាប់ចោទ ត្រូវទទួលការសន្មត់ជាមុនថា គ្មានកំហុសជាដាច់ខាត ។

## មាត្រា ២៦ : អំពីសាលក្រម

១ : គ្រប់សាលក្រមព្រហ្មទណ្ឌត្រូវប្រកាស «ក្នុងនាមប្រជាជាតិកម្ពុជា» សាលក្រមត្រូវទង្អុលអំពើដែលចោទប្រកាន់លើជនជាប់ចោទ ចង្អុលសាក្សី ឬ ភស្តុតាង ដែលចាត់ទុកជាត្រឹមត្រូវ ហើយដែលមានចែងមូលហេតុច្បាស់លាស់ ក្នុងការផ្តន្ទាទោស ។

២ : សាលក្រមដែលមានមូលហេតុច្បាស់លាស់ស្តីពីការផ្តន្ទាទោស និងសេចក្តីវិនិច្ឆ័យ ត្រូវអានទៅក្នុងពេលសវនាការ ។ សេចក្តីចម្លងសាលក្រមមួយច្បាប់ នឹងចែកជូនដល់ភាគីទាំងអស់ តាមសេចក្តីសុំរបស់គេ ។

## មាត្រា ២៧ : ការតាំងខ្លួនជាភាគីរដ្ឋប្បវេណី

១ : ជនរងគ្រោះ ឬ សិទ្ធិវន្តរបស់ជនរងគ្រោះទាំងឡាយ ដោយផ្ទាល់ ឬតាមរយៈទីប្រឹក្សា អាចតាំងខ្លួនជាភាគីរដ្ឋប្បវេណី នៅពេលអង្កេតស៊ើបសួរ ឬពេលសវនាការជំនុំជំរះ ដើម្បីទារសំណងជម្ងឺចិត្តពីអ្នកប្រព្រឹត្ត ឬដៃគូអ្នកប្រព្រឹត្តបទល្មើស និងអ្នកសមគំនិតក្នុងបទល្មើស ។ ទីប្រឹក្សារបស់អ្នកទាំងនោះ មានសិទ្ធិពិនិត្យសំណុំរឿង ដូចជនជាប់ចោទដែរ ។

២ : ជនប្រព្រឹត្តបទល្មើស និងអ្នកសមគំនិត ត្រូវទទួលខុសត្រូវរួម ក្នុងការជួសជុល ឬសងជំងឺចិត្ត ក្នុងលក្ខណៈទាំងឡាយដែលឆ្លើយតបទៅនឹងការតម្រូវនៃ *សេចក្តីថ្លែងការណ៍ ស្តីអំពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌ ទាក់ទិនទៅនឹងជនរងគ្រោះពីបទឧក្រិដ្ឋ និងជនរងគ្រោះពីការរំលោភអំណាច* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

## មាត្រា ២៨ : បទល្មើសក្នុងការសំដែងមតិ

១ : គ្មានជនណាម្នាក់ត្រូវគេយាយីរំខានពីរឿងមតិនយោបាយ ជំនឿសាសនា និងពីការដែលខ្លួនជាប់ពូជសាសន៍ ឬជាតិពន្ធណាមួយឡើយ ។

២ : ច្បាប់ព្រហ្មទណ្ឌទាំងឡាយ ដែលមានជាធរមានសព្វថ្ងៃទូទាំងប្រទេសកម្ពុជា មិនអាចយកមកសំអាងលើបទល្មើសក្នុងការសំដែងមតិនយោបាយ ឬបទល្មើសមនោគមន៍វិជ្ជាទៀតឡើយ ហើយត្រូវទុកជានិរាករណ៍ ។

## មាត្រា ២៩ : ការពិនិត្យសារឡើងវិញលើរឿងក្តីខ្លះ

ជនដែលត្រូវបានជំនុំជំរះរួចហើយក្តី អាច ដោយខ្លួនឯង ឬតាមរយៈទីប្រឹក្សា ឬមេធាវី សុំអោយស៊ើបពិនិត្យរឿងក្តីសារជាថ្មី បើសិនជាយល់ថាខ្លួនត្រូវគេផ្តន្ទាទោសក្នុងមូលដ្ឋានគំនិតមតិ, សេចក្តីថ្លែងការណ៍, ការដែលខ្លួនជាប់ ឬមិនជាប់ពូជសាសន៍, ជាតិពន្ធ, សាសនា, នយោបាយ និង សង្គម ។

## ៣-អំពីអាជ្ញាយុកាល :

### <u>មាត្រា ៣០ : អាជ្ញាយុកាល</u>

អាជ្ញាយុកាលសំរាប់បទមជ្ឈិមមានរយៈពេលបីឆ្នាំ រីឯអាជ្ញាយុកាលសំរាប់បទឧក្រិដ្ឋមានរយៈពេលដប់ឆ្នាំ។ អាជ្ញាយុកាលត្រូវចប់នៅពេលណាសកម្មភាពនីតិវិធីទាំងអស់បានសម្រេច ។

- អាជ្ញាយុកាលបទមជ្ឈិមមានរយៈពេល ៣ ឆ្នាំ
- អាជ្ញាយុកាលបទឧក្រិដ្ឋមានរយៈពេល១០ ឆ្នាំ
- អាជ្ញាយុកាលបទលហុមាន[illegible]ៈពេល [illegible] ឆ្នាំ

អាជ្ញាយុកាលត្រូវចប់នូវពេលវេលាណាសកម្មភាពនីតិវិធីទាំងនេះត្រូវបានសំរេច ។

# កិច្ចតែងការបង្រៀន

# កិច្ចតែងការបង្រៀន

**ចំណងជើង: មេរៀនទី១ អំពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ**

**មេរៀនទី២ អំពី សិទ្ធិសេដ្ឋកិច្ច និង វប្បធម៌**

| ពេលវេលា | គោលដៅជាក់លាក់ | វិធីសាស្ត្រ | សម្ភារៈជំនួយ | សំនួរស្នាបស្ទង់ | ចំលើយ |
|---|---|---|---|---|---|
| 80 នាទី | .សិក្សាការយល់បានន្ទូវ អំពី សិទ្ធិពលរដ្ឋ | .សំនួរបំផុសគំនិត | .ក្រដាសធំ .ហ្វឺតធំ | .អ្វីទៅជាសិទ្ធិមនុស្ស ? | .សិទ្ធិមនុស្សត្រូវបានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស សិទ្ធិកុមារ និង សិទ្ធិស្ត្រី ។ .អង្គការសហប្រជាជាតិអនោម័តអោយប្រើប្រាស់នាថ្ងៃទី១៦ខែធ្នូឆ្នាំ៦៦ .កម្ពុជាទទួលយកមកដាក់បញ្ចូលរដ្ឋធម្មនុញ្ញជំពូកទី៣ មាត្រា៣១ និង មាត្រាទី៣២ . |
| | | | | .ចូរអោយនិយមន័យសិទ្ធីមនុស្សយ៉ាងដូចម្តេច ? | .សិទ្ធិមនុស្សគឺជាការរស់រានមានជីវិតដ៏មានតំលៃ និង សេចក្តីថ្លៃថ្នូរក្នុងភាពមនុស្សទាំងអស់កំណើត ។ |
| | | | | .សិទ្ធិប្រជាពលរដ្ឋមាននៅមា | .ជំពូកទី ៣ មាត្រា ៣១ និង មាត្រា |

| | | | | គ្រាណា? ក្នុងជំពូកទីប៉ុន្មាន ? | ៣២ ( អានសៀវភៅ ធម្មនុញ្ញ) |
|---|---|---|---|---|---|
| 40នាទី | . សិក្ខាកាមយល់បាននូវ ស្តីពី សិទ្ធី នយោបាយ | . សំនួរបំផុសគំនិត | .ក្រដាស<br>.ហ្វឺតធំ | .សិទ្ធិនយោបាយមាននៅក្នុងជំពូកទីប៉ុន្មាន? មាត្រាទីប៉ុន្មាន? ក្នុងរដ្ឋធម្មនុញ្ញ | .ជំពូកទី ៣ មាត្រា ៣៤ និង មាត្រា ៣៥ ក្នុងរដ្ឋធម្មនុញ្ញ . |
| 60នាទី | . សិក្ខាកាមយល់បាននូវ ស្តីពី សិទ្ធិសេដ្ឋកិច្ចសង្គម | . សំនួរបំផុសគំនិត | . ក្រដាស<br>.ហ្វឺតធំ | .សិទ្ធិសេដ្ឋកិច្ចសង្គមមាននៅក្នុង ជំពូកទីប៉ុន្មាន? មាត្រាទីប៉ុន្មាន? ក្នុងរដ្ឋធម្មនុញ្ញ. | . ជំពូកទី ៣ មាត្រា ៣៦ និង មាត្រា ៤៤ ក្នុងរដ្ឋធម្មនុញ្ញ . |
| 120នាទី | . សិក្ខាកាមយល់បាននូវ ស្តីពី សិទ្ធិវប្បធម៌ | . សំនួរបំផុសគំនិត | . ក្រដាស<br>. ហ្វឺតធំ | .សិទ្ធិនយោបាយមាននៅក្នុងជំពូកទីប៉ុន្មាន? មាត្រាទីប៉ុន្មាន? ក្នុងរដ្ឋធម្មនុញ្ញ.<br>.ដើម្បីរស់នៅជាមនុស្សកើតតើយើងត្រូវការធ្វើខ្លះ ? | . ជំពូកទី ៣ មាត្រា ៤៣ និង មាត្រា ៤៨ ក្នុងរដ្ឋធម្មនុញ្ញ .<br>. តារាងប្រៀបធៀបសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ និង សិទ្ធិសេដ្ឋកិច្ចសង្គម និង វប្បធម៌.<br>. សាកលភាព នៃ សិទ្ធិមនុស្ស<br>. ភាពមិនអាចកាត់ចេញពីគ្នា នៃ សិទ្ធិមនុស្ស . សិទ្ធិមានជំរកសមរម្យ ឬមានកម្ម សិទ្ធិដីធ្លី . |

# កិច្ចតែងការបង្រៀន

**ចំណងជើង: មេរៀនទី ៣ ស្តីពី ករណីកិច្ចរបស់ប្រជាពលរដ្ឋ**

| ពេលវេលា | គោលដៅជាក់លាក់ | វិធីសាស្ត្រ | សម្ភារៈជំនួយ | សំនួរស្នាបស្ទង់ | ចំលើយ |
|---|---|---|---|---|---|
| 40នាទី | . សិក្ខាកាមយល់បានអំពី និតិវិធីច្បាប់ព្រហ្មទណ្ឌ. | . សំនួរបំផុសគំនិត<br>. ឧទាហរណ៍ | .ក្រដាសធំ<br>.ហ្វឺតធំ | .អំពីនិតិវិធីច្បាប់ព្រហ្មទណ្ឌ មាននៅក្នុងមាត្រាទីប៉ុន្មាន? ក្នុង រដ្ឋធម្មនុញ្ញ. | .មានមាត្រា ១០.មាត្រា៣៩ និង មាត្រា ៣៦ ក្នុងរដ្ឋធម្មនុញ្ញ . |
| 40នាទី | .សិក្ខាកាមយល់បានការសរសេរពាក្យបណ្តឹងព្រហ្មទណ្ឌ | .ឧទាហរណ៍រឿង | . ក្រដាសធំ<br>.ហ្វឺតធំ | .តើដែលធាប់ធ្វើពាក្យបណ្តឹងដែរឬទេ ?បើដែរធ្វើយ៉ាងដូចម្តេច? | . មានគំរូពាក្យបណ្តឹង . ការសរសេរ និង ពន្យល់បែបបទតាមផ្លូវការរបស់ នៃ រដ្ឋ. |
| 40នាទី | .សិក្ខាកាមយល់បានការសរសេរពាក្យបណ្តឹងរដ្ឋប្បវេណី. | .ឧទាហរណ៍រឿង | . ក្រដាសធំ<br>.ហ្វឺតធំ | .តើដែលធាប់ធ្វើពាក្យបណ្តឹងដែរឬទេ ?បើដែរធ្វើយ៉ាងដូចម្តេច? | . មានគំរូពាក្យបណ្តឹង . ការសរសេរ និង ពន្យល់បែបបទតាមផ្លូវការរបស់ នៃ រដ្ឋ. |
| 40នាទី | .សិក្ខាកាមយល់បានការសរសេរពាក្យបណ្តឹង. | .ឧទាហរណ៍រឿង | . ក្រដាសធំ<br>.ហ្វឺតធំ | .តើដែលធាប់ធ្វើពាក្យបណ្តឹងដែរឬទេ ?បើដែរធ្វើយ៉ាងដូចម្តេច? | . មានគំរូពាក្យបណ្តឹង . ការសរសេរ និង ពន្យល់បែបបទតាមផ្លូវការរបស់ នៃ រដ្ឋ. |
| | .សិក្ខាកាមយល់បានការសរសេរ | .ឧទាហរណ៍រឿង | . ក្រដាសធំ | .តើដែលធាប់ធ្វើពាក្យបណ្តឹង | . មានគំរូពាក្យបណ្តឹង . ការ |

| | | | | | |
|---|---|---|---|---|---|
| 40ᨂ8 | ពាក្យបណ្ដឹងតវ៉ា<br>• | | .ហ៊ឹតធំ | ដែរឬទេ ?បើដែរធ្វើយ៉ាងដូចម្ដេច? | សរសេរ និង ពន្យល់បែបបទតាមផ្លូវការរបស់ នៃ រដ្ឋ. |
| 40ᨂ8 | .សិក្សាកាមយល់បានការសរសេរពាក្យបណ្ដឹងសារទុក្ខ | .ឧទាហរណ៍រឿង | . ក្រដាសធំ<br>.ហ៊ឹតធំ | .តើដែលធ្លាប់ធ្វើពាក្យបណ្ដឹងដែរឬទេ ?បើដែរធ្វើយ៉ាងដូចម្ដេច? | . មានគំរូពាក្យបណ្ដឹង . ការសរសេរ និង ពន្យល់បែបបទតាមផ្លូវការរបស់ នៃ រដ្ឋ. |

## គំរូផែនការបង្រៀន

**ចំណងជើង : មេរៀនទី ៤ / ៥ ស្តីពី រចនាសម្ព័ន្ធតុលាការ និង និតិវិធីច្បាប់** (បទបញ្ញត្តិ ស្តីពី ប្រពន្ធ័តុលាការច្បាប់ព្រហ្មទណ្ឌ និង និតិវិធីព្រហ្មទណ្ឌសំរាប់ប្រទេសកម្ពុជា )

| ពេលវេលា | គោលដៅជាក់លាក់ | វិធីសាស្ត្រ | សម្ភារៈជំនួយ | សំនួរស្នោបស្ទង់ | ចំលើយ |
|---|---|---|---|---|---|
| 80នាទី | . សិក្ខាកាមយល់បានអំពី រចនាសម្ពន្ធ័តុលាការ. | .សំណួរចោទចំលើយ | .ក្រដាសធំ<br>.ហ្វឺតធំ | . អំពី រចនាសម្ពន្ធ័តុលាការ មាននៅក្នុងមាត្រាទីប៉ុន្មាន? ក្នុង ប្រពន្ធ័តុលាការច្បាប់ព្រហ្មទណ្ឌនិងនិតិវិធីព្រហ្មទណ្ឌសំរាប់ប្រទេសកម្ពុជា. | .មានក្នុងមាត្រា១.២.៣.៤ .៥.៦. ៨ និង មាត្រា ៩ក្នុងប្រពន្ធ័តុលាការច្បាប់ព្រហ្មទណ្ឌ និងនិតិវិធីព្រហ្មទណ្ឌសំរាប់ប្រទេសកម្ពុជា . |
| 45នាទី | .សិក្ខាកាមយល់បានអំពី ជំនួយផ្នែកច្បាប់. | .សំណួរចោទចំលើយ | .ក្រដាសធំ<br>.ហ្វឺតធំ | . អំពី ជំនួយផ្នែកច្បាប់មាននៅក្នុងមាត្រាទីប៉ុន្មាន? ក្នុង ប្រពន្ធ័តុលាការច្បាប់ព្រហ្មទណ្ឌនិងនិតិវិធីព្រហ្មទណ្ឌសំរាប់ប្រទេសកម្ពុជា. | .មានក្នុងមាត្រា១០.១១.១២.១៣.១៤.១៥.១៦.១៧.១៨. និង មាត្រា១៩ក្នុងប្រពន្ធ័តុលាការ ច្បាប់ព្រហ្មទណ្ឌ និង និតិវិធីព្រហ្មទណ្ឌសំរាប់ ប្រទេសកម្ពុជា . |
| 60នាទី | .សិក្ខាកាមយល់បានអំពី ជំនួយផ្នែកច្បាប់. | .សំណួរចោទចំលើយ | .ក្រដាសធំ<br>.ហ្វឺតធំ | .អំពីវិធីកាត់ក្តីហេតុ នៅក្នុងមាត្រាទីប៉ុន្មាន ? ក្នុងប្រពន្ធ័តុលាការច្បាប់ព្រហ្មទណ្ឌនិងនិតិវិធី ព្រហ្មទណ្ឌសំរាប់ ប្រទេសកម្ពុជា. | .មានក្នុងមាត្រា២៣.២៤.២៥.២៦.២៧.២៨.២៩ និង មាត្រា ៣០ ក្នុងប្រពន្ធ័តុលាការ ច្បាប់ព្រហ្មទណ្ឌ និង និតិវិធីព្រហ្មទណ្ឌសំរាប់ ប្រទេសកម្ពុជា |

# លទ្ធផលទាយតំលៃទក្ខ

# លទ្ធផលវាយតម្លៃវគ្គបណ្តុះបណ្តាលអំពី
# មូលដ្ឋានគ្រឹះក្នុងការស្វែងយល់អំពីច្បាប់ ដល់ជនបង្គោល
# សហគមន៍នេសាទធ្វើថ្ងៃទី ១៦-១៨ ខែ កុម្ភៈ ឆ្នាំ ២០០៤
# នៅសាលាបណ្តុះបណ្តាលមន្ទីរសុខាភិបាលខេត្ត កំពង់ធំ

១- វិធីសាស្រ្តអ្នកសំរបសំរួល :

| ល្អ | មធ្យម | ខ្សោយ |
|---|---|---|
| ២០ នាក់ | ៣ នាក់ | ០ |

២- មេរៀនស្តីពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ :

| យល់ល្អ | មធ្យម | ខ្សោយ |
|---|---|---|
| ១៩ នាក់ | ២ នាក់ | ១ នាក់ |

៣- មេរៀនស្តីពី សិទ្ធិសេដ្ឋកិច្ច និង វប្បធម៌ :

| យល់ល្អ | មធ្យម | ខ្សោយ |
|---|---|---|
| ១៨ នាក់ | ៣ នាក់ | ២ នាក់ |

៤- មេរៀនស្តីពី ករណីរបស់ប្រជាពលរដ្ឋ:

| យល់ល្អ | មធ្យម | ខ្សោយ |
|---|---|---|
| ២០ នាក់ | ៣ នាក់ | ០ |

៥- មេរៀមស្តីពី រចនាសម្ព័ន្ធតុលាការ :

| យល់ល្អ | មធ្យម | ខ្សោយ |
|---|---|---|
| ១៨ នាក់ | ១ នាក់ | ៣ នាក់ |

៦- មេរៀនស្តីពី នីតិវិធីច្បាប់ :

| យល់ល្អ | មធ្យម | ខ្សោយ |
|---|---|---|
| ១០ នាក់ | ១០ នាក់ | ៣ នាក់ |

៧- ទីកន្លែងប្រជុំ និង ស្នាក់នៅ :

| ល្អ | មធ្យម | ខ្សោយ |
|---|---|---|
| ២៣ នាក់ | 0 | 0 |

៨- សំនូមពរ និង យោបល់ផ្សេងៗ :

១- បើកវគ្គនេះបន្ត

២- ធ្វើកម្មវិធីសំនួរចំលើយជាមួយអ្នកច្បាប់នេះទៀត

៣- សូមសៀវភៅពីច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ភូបាល និង ព្រហ្មទណ្ឌ

៤- សូមពីលែអាហារបន្ថែមទៀត